# រឿង មហាចោរនៅទល់ដែន

**ភាគទី៦៨** (ផែនការសម្ងាត់)

ថាតែប៉ុណ្ណោះ តាគីរីបោះសំបុត្រប្រួលលើតុ។ មានន្ទក្រសារយកភ្លាមមកបើកឃើញអក្សរ។ បុរសស្គាល់ជាក់ជាអក្សរទេវី។ បុរសហៀបគ្រវាត់សំបុត្រចោក តែតាគីរីមុខស្មើបែបខឹង។ បុរសត្រជាក់អស់ខ្លួនប្រាណ រួចប្រឹងមើលសេចក្តីដូចតទៅ:

ក្នុងព្រៃ ថ្ងៃទី១៥កើត ខែបុស្ស គ.ស ១៨៦៧

លំអោនគោរពចំពោះបងមានន្ទជាទីគោរព

ក្នុងពេលដែលបងកំពុងមើលសំបុត្ររបស់ប្អូននេះ ព្រលឹងប្អូនកំពុងស្ថិតនៅក្នុងពពកនាស្ថានទេវលោក។

ក្នុងស្ថានថ្មីនេះ ប្អូនបានសុខសប្បាយក្រៃណានឹងរកអ្វីមកផ្ទឹមពុំបានឡើយ។

ចោលកន្ទុយភ្នែកមកមើលស្ថានមនុស្សវិញ ប្អូនសើចព្រោះឃើញបងហែលឆ្លងវដ្តសង្សារលំបាកដូចប្អូនបានហែល ឆ្លងរួចមកហើយ។

ថ្ងៃមួយដល់បងដល់ត្រើយសុខដូចប្អូន បងនឹងឈរមើលអ្នកជាន់ក្រោយ។ ប្រវេប្រវាហែលឆ្លងដូចយើងទៀតពុំខាន រួចបងមុខជាសើចដូចខ្ញុំសើចនឹងបងក្នុងពេលនេះ។

ឱ! ប្អូនថាបងកំពុងហែលក្នុងសមុទ្រទុក្ខដូចប្អូនបានហែលឆ្លងនោះខុសទេ ព្រោះថាទុក្ខប្អូនខុសអំពីទុក្ខបងស្រឡះ។

ទុក្ខប្អូន គឺទុក្ខស្នេហាលើរូបបង។

ក្នុងមួយជាតិនេះ ប្អូនបានទទួលស្នេហាតបពីបងវិញ តែត្រឹមថ្ងៃបងបែកពីប្អូនទៅច្បាំងប៉ុណ្ណោះទេ។ ចាប់ពីពេលដ៏អស្ចារ្យនោះមក គឺប្អូនមានទុក្ខរហូតដល់ដាច់ខ្យល់ស្លាប់។ ដោយប្អូនបានដល់ត្រើយសុខទៅហើយ ប្អូនខ្លាចអីនឹងរំលឹកល្បែងស្នេហា ដែលប្អូនបានលេងជាមួយបង។ គឺថាប្អូនបានស្គាល់ទីវាងងឹតបំផុតរបស់ស្ត្រីកំព្រាព្រាត់ប្តី។ បងនឹកឃើញទេបងទៅច្បាំងប្អូនចាំ ៗៗ ចាំបាត់ៗ។ ប្អូនបីកូនចាំមើលផ្លូវបង។ ទឹកភ្នែកហូរៗ ជាថ្លុក ជាអូរ ជាស្ទឹង ជាទន្លេ ជាសមុទ្រ។ សម្រេចបងមិនឃើញត្រឡប់មកសោះ។

អត្ថបទដោយ៖ មាស សុភាព

ថ្ងៃបងមកដល់។ ប្អូនស្មានថា ប្អូនផុតទុក្ខដែលធ្លាប់រួមរឹតប្អូនហើយ។ តែឥតដូច្នោះទេ បងមិនយល់ចិត្តប្អូន បងខឹងនឹងប្អូន ដោយគេចោទប្អូននោះ ជ្រុលពេកហួសវិស័យប្អូន។

ប្អូនមិនបន្ទោសបងថា មិនចេះពិចារណាឲ្យវែងឆ្ងាយនោះទេ ពីព្រោះឥឡូវនេះប្អូនដឹងច្បាស់ថាធម្មតាមនុស្សតែងភ័ន្តច្រលំជានិច្ច។

ដល់ពេកក្រោយប្អូនពកូនតាមបងដើម្បីទៅពន្យល់បង និយាយនឹងបងថាបើរឿងពិតដែលប្អូនស្រលាញ់បងនោះ ពុំគាប់ចិត្តបងទេពេលនោះប្អូនប្រាថ្នាថា ប្អូនសុំផ្ដាច់ជីវិត។ តែរកបងមិនឃើញសោះ។

ទុក្ខប្អូនក៏ចេះតែមានរាល់ថ្ងៃ រាល់ខែ រាល់ឆ្នាំទៀត។

ថ្ងៃមួយ មនុស្សម្នាក់បានជួយប្អូន និងបទុមកូនឲ្យរួចពីកណ្ដាប់ដៃកាមា។ មនុស្សដ៏សប្បុរសនេះបាននាំប្អូនទៅរកបងឯឃុំថ្មីស្រុកភ្លៀត ដោយបានជួយលាក់បំពួនប្អូនឥតឱ្យអ្នកណាដឹងឡើង។

ពេញមួយឆ្នាំគត់ ប្អូនលបមើលឃើញតែគេឯទៀត ឯរូបបងមិនដែលឃើញ។ ប្អូនក៏ឈឺចាប់ៗ ៗ ឱ!ឈឺត្រាតែ...ដូច បងជ្រាប។

នេះហើយពណ៌សមុទ្រដែលបងកំពុងហែលវិញនោះយ៉ាងណា?

ដំបូងបងហែលម្នាក់ឯង គ្មានគូ! ចំណាប់មែន! ជាពិសេសជីវិតបងជាជីវិតតស៊ូ តស៊ូនឹងធម្មជាតិ តស៊ូនឹងខ្មាំង តស៊ូនឹងកិច្ចការ។ ប្រសើរពេក។ ជីវិតបងខុសពីជីវិតអ្នកឯទៀត។ ទុក្ខរបស់បង គឺទុក្ខរបស់រាស្ត្រខ្មែរ។ ក្ដីវេទនារបស់បង គឺក្ដីវេទនារបស់សង្គមខ្មែរ បងមានការធ្វើច្រើន។ គឺកិច្ចការនេះហើយ ដែលបំភ្លេចបងមិនឲ្យនឹកនាដល់ប្អូនដែលស្រលាញ់បង ហើយមិនឲ្យនឹកនាដល់ស្ត្រីឯទៀត។ ដូចនេះ បងជ្រាបរឿងយើងហើយ! ប្អូនសូមលាហើយណាបងសម្លាញ់។

ឱ! បងភ័យក្រែងប្អូនចងពៀរនឹងបងឬ? ទេកុំភ័យដល់ថ្ងៃដែលមានមច្ចុរាជ អញ្ជើញបងឲ្យចាកផុតស្ថានកណ្ដាល ថ្ងៃនោះប្អូនរង់ចាំទទួលបងមិនខាន។

នៅចុងក្រោយបំផុត ប្អូនសូមឲ្យបងមានជ័យជម្នះក្នុងដំណើរការរបស់បង ដើម្បីជាតិខ្មែរ ដើម្បីប្រទេសខ្មែរ និងដើម្បីប្រជាជាតិខ្មែរ។

ដោយសេចក្ដីរាប់អានយ៉ាងខ្ពង់ខ្ពស់!

ទេវី

អត្ថបទដោយ៖ មាស សុភាព

អានសំបុត្រនេះចប់ទឹកភ្នែកពីដំណក់ស្រក់ម៉ាត់ៗពីភ្នែកមានន្ទ។ តាគីរីនៅស្ងៀម។ មានន្ទខាំធ្មេញប្រឹងបង្ក្រាប តណ្ហាដែលត្រឡប់មកគ្របដណ្ដប់ខ្លួនវិញ។ តណ្ហានេះដែឡក្រាបស្រពោនយូរមក ហើយស្រាប់តែងើបផុសស្ទុះឡើងបីដូចទឹកដែលបាក់ទំនប់។ ទឹកនេះហូរខ្លាំងក្រៃណាខ្លាំង ធ្វើឲ្យវីរបុរសវិលក្បាលព្ទសូរងឹង។ ហូតកូនកាំបិតស្នៀតភ្លែតមានន្ទ ប្រឹងអស់ទំហឹងលើកបុកចុងដង្ហើមដោយឥតនិយាយមួយម៉ាត់ឡើយ។ កូនកាំបិទស្រាប់តែខ្ទាតផឹងរបូតពីដៃធ្លាក់ទៅចំហៀងជាមួយកូនកាំបិតមួយទៀត។

តាគីរីញញឹមស្ងួតមើលមុខមានន្ទដែលញ័រអស់ទាំងខ្លួន។ តាគីរីក្រោកឡើងដើរមួយៗទៅរើសកូនកាំបិតរបស់គាត់ ដែលបានចោលទៅត្រូវកូនកាំបិតមានន្ទ កាលមានន្ទលើកចាក់ខ្លួនឯង។ មានន្ទស្ទុះទៅទ្រោបលើពូកយំដូចក្មេងព្ទសូរយឹកៗ គឺជាលើកដំបូងក្នុងមួយជីវិតនេះដែលយើងមានន្ទយំ។

តាគីរីដកដង្ហើមធំ យកថ្នាំញាត់ខ្សៀជាថ្មី អុជរួចបឺតខ្សៀយ៉ាងស្ងប់ស្ងៀម។

ឱ! មានន្ទយំមែន! ហេតុតែចិត្តក្មេង! ចេះតស៊ូចេះមានគំនិតទូលាយហ៊ានលះបង់បុណ្យសក្តិទ្រព្យសម្បត្តិ សេចក្តីស្នេហា ចេះគិតរៀបអង្គការបដិវត្តយ៉ាងល្អ ចេះមានប្រាជ្ញាវៃឆ្លាត ចេះគិតឃើញខុសត្រូវឥឡូវអំពើពាលរត់ចូលមកនាំដៃឲ្យធ្វើ ឃាតកម្មខ្លួនឯង! ហ៊ឹះអស្ចារ្យមែន! ចិត្តក្មេង! នាមឈ្មោះល្អក្រអូប! បើឆ្ងាយមួយពេលនេះឲ្យមោហ៍មកបាំងបានអស់ហើយ! ចប់ហើយ! អស់កើតជាមនុស្សហើយ អស់ទៅជាខ្មែរស្នេហាជាតិហើយ!

**(សូមរង់ចាំតាមដានភាគទី៦៩ នៅសប្តាហ៍ក្រោយ)**

KHMER CIVILIZATION

អត្ថបទដោយ៖ មាស សុភាព